**វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ**
**មុខវិជ្ជាស្រាវជ្រាវអប់រំ**
**សម្រាប់គរុនិស្សិតឆ្នាំទី៣ ឆមាសទី១**

# ការសិក្សាបែបគម្រោង សប្តាហ៍ទី ១៤
# ប្រធានបទ៖ ការស្វែងយល់ពីថាមវន្ត (Dynamics) និងវប្បធម៌នៃការរៀនក្នុងថ្នាក់បឋមសិក្សា

## ១. សេចក្តីផ្តើម

គម្រោងនេះមានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវបទពិសោធន៍ជាក់ស្តែងក្នុងការអនុវត្តវិធីសាស្រ្តស្រាវជ្រាវគុណវិស័យ ដើម្បីស្វែងយល់ពីថាមវន្ត (សក្តានុពលដ៏ស្មុគស្មាញ)នៃថ្នាក់រៀនបឋមសិក្សា។ ជំនួសឱ្យការសិក្សាសហគមន៍ទូទៅ គរុនិស្សិតនឹងផ្តោតការយកចិត្តទុកដាក់លើថ្នាក់រៀនមួយជាករណីសិក្សា ដោយប្រើប្រាស់បច្ចេកទេសសង្កេត និងសម្ភាស ដើម្បីស្វែងយល់ពីអន្តរកម្ម យុទ្ធសាស្រ្តបង្រៀន និងបរិយាកាសនៃការរៀន។

## ២. វត្ថុបំណង

នៅពេលបញ្ចប់គម្រោងនេះ គរុនិស្សិតនឹងអាច៖

- ផ្តល់ឱ្យគរុនិស្សិតនូវ **បទពិសោធន៍ជាក់ស្តែង** ក្នុងការអនុវត្តវិធីសាស្រ្តស្រាវជ្រាវបែបគុណភាព (ការសង្កេត និងសម្ភាស) សម្រាប់ធ្វើការសិក្សាស្វែងយល់ឱ្យបានស៊ីជម្រៅអំពី **សក្តានុពលដ៏ស្មុគស្មាញ** នៃថ្នាក់រៀនកម្រិតបឋមសិក្សា។

## ៣. សំណួរណែនាំ (Driving Question)

តើអន្តរកម្មរវាងគ្រូ-សិស្ស និងសិស្ស-សិស្ស នៅក្នុងសកម្មភាព [ឧ. ការងារក្រុម, ការអាន, ការដោះស្រាយលំហាត់] ក្នុងមុខវិជ្ជា [ឧ. គណិតវិទ្យា, ភាសាខ្មែរ] ថ្នាក់ទី [ឧ. ទី៣, ទី៤] បង្ហាញពីវប្បធម៌នៃកាrr[n ក្នុងថ្នាក់រៀននោះអ្វីខ្លះ?

## ៤. ដំណាក់កាលនៃគម្រោង

ជំហានទី១៖ ការរៀបចំផែនការ

- បង្កើតក្រុម (៣-៤ នាក់) និងជ្រើសរើសប្រធានបទសិក្សា៖
    - "ថាមវន្តនៃការងារក្រុមក្នុងមុខវិជ្ជាគណិតវិទ្យា ថ្នាក់ទី៤"
    - "ការប្រៀបធៀបកម្រិតចូលរួមរបស់សិស្សប្រុស-ស្រីក្នុងមុខវិជ្ជាវិទ្យាសាស្រ្ត ថ្នាក់ទី៥"
    - "ឥទ្ធិពលនៃយុទ្ធសាស្រ្តគ្រប់គ្រងថ្នាក់រៀនរបស់គ្រូទៅលើអាកប្បកិរិយារបស់សិស្ស"
- **រៀបចំសំណើគម្រោង (១ ទំព័រ)៖** រៀបរាប់ពីសំណួរស្រាវជ្រាវ ថ្នាក់រៀនគោលដៅ (បើអាច) និងផែនការសកម្មភាព។
- បង្កើតឧបករណ៍ស្រាវជ្រាវ៖
    - **ទម្រង់សង្កេតក្នុងថ្នាក់រៀន៖** បង្កើតបញ្ជីត្រួតពិនិត្យ (Checklist) ឬគំរូកត់ត្រា ដែលផ្តោតលើអាកប្បកិរិយាជាក់លាក់ (ឧ. ការលើកដៃ, ការសួរសំណួរ, ការធ្វើការរួមគ្នា)។

    - **មគ្គុទ្ទេសក៍សម្ភាស៖** រៀបចំសំណួរសម្រាប់សម្ភាស **គ្រូបង្រៀនប្រចាំថ្នាក់** (ជាកាតព្វកិច្ច) និង **សិស្ស ២-៣ នាក់** (ប្រសិនបើអាច និងមានការអនុញ្ញាត)។

ជំហានទី២៖ ការប្រមូលទិន្នន័យ

- **សុំការអនុញ្ញាត៖** ក្រុមនីមួយៗត្រូវទទួលខុសត្រូវក្នុងការសុំការអនុញ្ញាតពីសាលារៀន គ្រូបង្រៀន និងអាណាព្យាបាល (ក្នុងករណីសម្ភាសសិស្ស)។
- **ធ្វើការសង្កេតក្នុងថ្នាក់រៀន៖** ធ្វើការសង្កេត (បែបមិនមែនជាអ្នកចូលរួម) យ៉ាងតិច **២ ម៉ោងសិក្សា** (មួយម៉ោងសិក្សាមានរយៈពេល ៤៥-៦០ នាទី) ក្នុងថ្នាក់រៀនគោលដៅ។
- ធ្វើការសម្ភាស៖
    - សម្ភាសគ្រូបង្រៀនប្រចាំថ្នាក់ ដើម្បីស្វែងយល់ពីទស្សនៈ យុទ្ធសាស្ត្រ និងបញ្ហាប្រឈមរបស់គាត់។
    - (ស្រេចចិត្ត) សម្ភាសសិស្ស ដើម្បីស្វែងយល់ពីបទពិសោធ និងទស្សនៈរបស់ពួកគេ។

ជំហានទី៣៖ ការវិភាគ និងការសរសេររបាយការណ៍

- ការវិភាគទិន្នន័យ៖
    - ពិនិត្យឡើងវិញនូវកំណត់ត្រាសង្កេត និងប្រតិចារឹកសម្ភាស។
    - ប្រជុំក្រុមដើម្បីកំណត់រក **ចំណុចសំខាន់ៗ (Key Themes)**។ ឧទាហរណ៍ "សិស្សប្រុសមានឥទ្ធិពលខ្លាំងលើការងារក្រុម" ឬ "គ្រូប្រើប្រាស់សំណួរបើកដើម្បីជំរុញការគិត"។
- រៀបចំរបាយការណ៍ករណីសិក្សា និងបទបង្ហាញ៖
    - សរសេររបាយការណ៍ (៣-៤ ទំព័រ) ដោយរៀបរាប់ពីការរកឃើញ និងភ្ជាប់ជាមួយភស្តុតាង (ការដកស្រង់សម្ដីដើមពីសម្ភាស ឬឧទាហរណ៍ពីការសង្កេត)។
    - រៀបចំស្លាយបទបង្ហាញ (១០ នាទី) ដើម្បីចែករំលែកលទ្ធផលស្រាវជ្រាវដល់ថ្នាក់រៀន។

## ៥. លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ (៤០ ពិន្ទុ)

- **ផែនការ និងឧបករណ៍ស្រាវជ្រាវ (១០ ពិន្ទុ)៖** ប្រធានបទមានភាពច្បាស់លាស់ ឧបករណ៍សង្កេត និងសម្ភាសសមស្របសម្រាប់បរិបទថ្នាក់រៀន។
- **ការប្រមូល និងវិភាគទិន្នន័យ (១០ ពិន្ទុ)៖** ការប្រមូលទិន្នន័យមានសីលធម៌ ការវិភាគអាចបង្ហាញពីចំណុចសំខាន់ៗដែលគួរឱ្យចាប់អារម្មណ៍និងស៊ីជម្រៅ។
- **របាយការណ៍ករណីសិក្សា (១០ ពិន្ទុ)៖** មានរចនាសម្ព័ន្ធច្បាស់លាស់ មានការប្រើប្រាស់ទិន្នន័យការផ្ទៀងផ្ទាត់ទិន្នន័យត្រឹមត្រូវ។
- **បទបង្ហាញ (១០ ពិន្ទុ)៖** បទបង្ហាញច្បាស់លាស់ គួរឱ្យចាប់អារម្មណ៍ និងបង្ហាញពីទំនាក់ទំនងរវាងទ្រឹស្ដីនិងការអនុវត្ត។